# លំនាំសម្រាប់ការរីកចម្រើន

ស្វែងរក សេចក្ដីត្រូវការ អំណោយទាន និងទេពកោសល្យរបស់អ្នក ។ សូមព្យាយាមសួរសំណួរដូចជា ៖

តើខ្ញុំមានអារម្មណ៍ថាគួររៀន ឬផ្លាស់ប្ដូរអ្វីខ្លះនៅក្នុងជីវិតរបស់ខ្ញុំ ?

តើអ្វីទៅជាទេពកោសល្យ និងជំនាញដែលខ្ញុំចង់ទទួលបាន ?

តើអ្វីទៅជាទម្លាប់ខាងវិញ្ញាណដែលខ្ញុំត្រូវការអភិវឌ្ឍ ឬកែលម្អ ?

តើខ្ញុំអាចរក្សាសេចក្ដីសញ្ញាដែលខ្ញុំបានធ្វើនៅពេលខ្ញុំទទួលបុណ្យជ្រមុជទឹកយ៉ាងដូចម្ដេច ?

តើខ្ញុំអាចបម្រើអ្នកណាខ្លះ ?

« អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយ . . . អ្នកត្រូវសូមដល់យើង បើសិនជាការណ៍នោះត្រឹមត្រូវ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩:៨ ) ។

ដាក់ផែនការ ដើម្បីធ្វើឲ្យប្រសើរឡើង ។ សូមព្យាយាមសួរសំណួរដូចជា ៖

- ហេតុអ្វីការណ៍នេះកើតឡើងចំពោះរូបខ្ញុំ ?
- តើវានឹងជួយខ្ញុំឲ្យកាន់តែប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?
- តើសកម្មភាពអ្វីទៅដែលជួយខ្ញុំឲ្យធ្វើការណ៍នេះ ?
- តើខ្ញុំអាចបំបែកសកម្មភាពទាំងនេះជាជំហានតូចៗជាងមុនបានទេ ?
- តើអ្វីទៅជាផែនការដែលខ្ញុំអាចធ្វើបាននៅពេលនេះ ដើម្បីយកឈ្នះលើឧបសគ្គដែលខ្ញុំអាចប្រឈម ?

« ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទនឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃទី២ ៣២:៣ ) ។

ឆ្លុះបញ្ចាំង ពីអ្វីដែលអ្នកបានរៀន ។ សូមព្យាយាមសួរសំណួរដូចជា ៖

- តើខ្ញុំបានរីកចម្រើនដោយរបៀបណា ?
- តើខ្ញុំអាចប្រើអ្វីដែលខ្ញុំបានរៀនដើម្បីបម្រើអ្នកដទៃដោយរបៀបណា ?
- តើទង្វើរបស់ខ្ញុំបានជួយខ្ញុំខិតកាន់តែជិតព្រះអង្គសង្គ្រោះដោយរបៀបណា ?
- តើខ្ញុំអាចបន្តរីកចម្រើននៅក្នុងចំណុចនេះដោយរបៀបណា ?

« ពិចារណាពីផ្លូវដែលជើងឯងដើរ » ( សុភាសិត ៤:២៦ ) ។

អនុវត្ត ដើម្បីរីកលូតលាស់ក្នុងសេចក្ដីជំនឿ ។ ប្រសិនបើអ្នកជាប់គាំង សូមព្យាយាមសួរសំណួរដូចជា ៖

- តើអ្វីដែលបានដំណើរការ ? ហេតុអ្វី ?
- តើអ្វីដែលមិនបានដំណើរការ ? ហេតុអ្វីមិនដំណើរការ ?
- តើខ្ញុំអាចធ្វើអ្វីខ្លះទៀត ?
- តើខ្ញុំអាចទទួលបានគំនិតបន្ថែមទៀតនៅកន្លែងណា ?
- តើខ្ញុំអាចបំបែកសកម្មភាពទាំងនេះជាជំហានតូចៗជាងមុនបានទេ ?
- តើខ្ញុំអាចរៀនមកពីភាពបរាជ័យយ៉ាងដូចម្ដេច ?

« យើងប្រាប់ជាប្រាកដថា [ អ្នក ] ត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ ហើយប្រព្រឹត្តអ្វីៗជាច្រើនតាមបំណងចិត្ត [ របស់អ្នក ] » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៨:២៧ ) ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_552-1